ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិព្រះវិហារ

# សេចក្ដីប្រកាសព័ត៌មាន

## អំពីការរួចផុតគ្រោះថ្នាក់របស់បុគ្គលិកអាជ្ញាធរជាតិព្រះវិហារ ចំនួន ៤៥ រូប ដែលជាប់គាំងនៅលើប្រាសាទព្រះវិហារ កាលពីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២៥

អាជ្ញាធរជាតិព្រះវិហារ មានកិត្តិយសជម្រាបជូនសាធារណជនទូទៅ មេត្តាជ្រាបថា បុគ្គលិកអាជ្ញាធរជាតិព្រះវិហារ ជាពលករ ភ្នាក់ងារទេសចរណ៍ កម្មករបរិស្ថាន និងសន្តិសុខសណ្ដាប់ធ្នាប់ ចំនួន ៤៥ រូប បានជាប់នៅលើភ្នំប្រាសាទព្រះវិហារអំឡុងពេលបំពេញការងារប្រចាំថ្ងៃ ដោយសារការវាយប្រហាររបស់កងកម្លាំងប្រដាប់អាវុធថៃ ដោយប្រើប្រាស់កាំភ្លើងធ្លោងធុនធ្ងន់ និងការទម្លាក់គ្រាប់បែកដោយយន្តហោះ F-16 នៅប្រាសាទព្រះវិហារនិងបរិវេណជុំវិញ ចាប់តាំងពីម៉ោង ៩:០០ នាទីព្រឹក ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥។

កាលពីម៉ោង២២:០០នាទីយប់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ អាជ្ញាធរជាតិព្រះវិហារបានសម្របសម្រួលជូនបុគ្គលិកទាំងអស់ធ្វើដំណើរថ្មើរជើងចុះពីលើភ្នំតាមចម្រាក់ភ្នំពើយតាឪរហូតមកដល់ភូមិធម្មជាតិសម្ដេចតេជោ ទើបឡើងរថយន្តរៀបចំដោយអាជ្ញាធរជាតិព្រះវិហារ បន្តដំណើរមកដល់ស្នាក់ការអាជ្ញាធរជាតិព្រះវិហារប្រចាំរមណីយដ្ឋានប្រាសាទកោះកេរវេលាម៉ោង ៦:០០នាទីព្រឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥ ដោយសុវត្ថិភាព បន្ទាប់ពីជាប់នៅលើភ្នំប្រាសាទព្រះវិហារ អស់រយៈពេល ៤៥ ម៉ោង។

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីអាជ្ញាធរជាតិព្រះវិហារ សូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក៏ដូចជាថ្នាក់ដឹកនាំក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គ្រប់បណ្ដាអង្គភាពពាក់ព័ន្ធ និងរដ្ឋបាលខេត្តព្រះវិហារគ្រប់លំដាប់ថ្នាក់ ដែលបានយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខ និងសម្រួលដល់ដំណើរការសង្គ្រោះបុគ្គលិកអាជ្ញាធរជាតិព្រះវិហារចាប់តាំងពីពេលជាប់នៅលើភ្នំប្រាសាទព្រះវិហាររហូតទទួលបានសុវត្ថិភាព។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសៅរ៍ ១កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅខេត្តព្រះវិហារ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥